# ជីវប្រវត្តិរបស់

# អ៊ីម៉ាំ អាល់-ហ៊ូសែន៍ صلوات الله عليه والسلام



សៃយីដ ម៉ាស់ឌ្ទី អាយ៉ាទុលឡ៍ហ៊ី

ស្ហាគីប បេនបេឌីវ៉ា

بسم الله الرحمن الرحيم

# បញ្ជីមាតិកា


១-អគ្គបុគ្គលទី ៥ ក្នុងចំណោមអគ្គបុគ្គល "អាល់-គីសាអ៊្(أهل الكساء)" ..... 4

២-អាល់-ហ៊ូសែន៍صلوات الله عليه والسلام អ្នកសង្គ្រោះសាសនាអ៊ីស្លាម ..... 7

៣-សីលធម៌របស់ព្រះរាជអគ្គមហាប្រមុខរបស់ទុក្ករបុគ្គលទាំងឡាយ ..... 17

៤-លោហិតឈ្នះផ្លែដាវ ..... 21

សង្ខេបព្រះវចនៈត្រចះត្រចង់របស់អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلام ..... 24

អត្តសញ្ញាណ ..... 25

## ១-អគ្គបុគ្គលទី ៥ ក្នុងចំណោមអគ្គបុគ្គល "អាល់-គីសាអ៊ុ(أهل الكساء)"

## កំណើត

អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلام រាជបុត្ររបស់អ៊ុាលីصلوات الله عليه والسلام បានប្រសូតនៅថ្ងៃទី ៣ ខែស្ហាក់ុបាន ឆ្នាំទី ៤ សករាជហ៊ីជ្រ៉េាះត៍។ ព្រះសាស្តាصلى الله عليه وآله وسلمមានសេចក្តីត្រេកអរអនេក។ ពេលព្រះអង្គصلى الله عليه وآله وسلمបានទទួលដំណឹង ព្រះអង្គصلى الله عليه وآله وسلمបានរត់សំដៅទៅរាជដំណាក់ព្រះរាជបុត្រីسلام الله عليهاព្រះអង្គصلى الله عليه وآله وسلمដើម្បីអបអរសាទរ។

ព្រះសាស្តាصلى الله عليه وآله وسلمបានប្រារព្ធពិធីទទួលកូនខ្ចី៖ ព្រះអង្គصلى الله عليه وآله وسلمសូត្រអាស៊ាន(أذان)ដាក់ត្រចៀកស្តាំកូនខ្ចី សូត្រអ៊ីក៏ម៉ាត់(إقامة)ដាក់ត្រចៀតឆ្វេងកូនខ្ចី ហើយបានបួងសួងផ្សេងៗទៀត។ បន្ទាប់មក ព្រះអង្គصلى الله عليه وآله وسلمបានដាក់ឈ្មោះឲ្យកូនខ្ចីថា អាល់-ហ៊ូសែន៍(الحسين)។

លុះអាល់-ហ៊ូសែន៍កើតបានប្រាំពីរថ្ងៃ អ៊ុាលីصلوات الله عليه والسلام ព្រះបិតារបស់ព្រះអង្គصلوات الله عليه والسلامបានធ្វើពិធីពលីកម្ម (អ៊ុាគ៊ីក្វោះត៍ عقيقة) ហើយបានចែកសាច់ឲ្យទៅជនតោកយ៉ាកនិងជនក្រីក្រ។

ព្រះសាស្តាصلى الله عليه وآله وسلمទ្រង់សព្វព្រះហឫទ័យអាល់-ហ៊ូសែន៍صلى الله عليه وآله وسلم ព្រះនត្តាប្រុសព្រះអង្គصلى الله عليه وآله وسلمណាស់។ ចាប់តាំងពីពេលព្រះអង្គصلى الله عليه وآله وسلمបានដឹងថាអាល់-ហ៊ូសែន៍صلوات الله عليه والسلامនឹងត្រូវគេសម្លាប់ក្នុងអនាគតកាល ព្រះអង្គصلى الله عليه وآله وسلمមិនអាចអត់ទ្រាំឮអាល់-ហ៊ូសែន៍صلى الله عليه وآله وسلمយំបានទេ។ ព្រះអង្គصلى الله عليه وآله وسلمតែងតែរំលឹកបណ្តាអ្នកដែលបានជួបព្រះអង្គصلى الله عليه وآله وسلمជាមួយព្រះនត្តាព្រះអង្គصلى الله عليه وآله وسلمថា៖ "អាល់-ហ៊ូសែន៍صلوات الله عليه والسلامមកពីខ្ញុំصلى الله عليه وآله وسلم ខ្ញុំصلى الله عليه وآله وسلمមកពីអាល់-ហ៊ូសែន៍صلوات الله عليه والسلام។ គេជាអ៊ីម៉ាំមួយរូបនិងជារាជបុត្ររបស់អ៊ីម៉ាំ។ នឹងមានអ៊ីម៉ាំប្រាំបួនរូបមកពីរាជបុត្ររាជនត្តារបស់គេصلوات الله عليه والسلام។ អ៊ីម៉ាំក្រោយគេបំផុតគឺអាល់-ម៉ាស្ទ៊ីعجل الله فرجك ដែលនឹងលេចខ្លួនឡើងនាអវសានកាលដើម្បីបំពេញផែនដីដោយយុត្តធម៌និងសមធម៌ ក្រោយពីវាបានពោរពេញដោយអយុត្តិធម៌និងអំពើអាក្រក់។

## សម័យកាលព្រះបិតា صلوات الله عليه والسلامព្រះអង្គ صلوات الله عليه والسلام

អាល់-ហ៊ូសែន៍صلوات الله عليه والسلامបានរស់នៅក្នុងសេចក្តីស្រឡាញ់ និងក្នុងការបីបាច់រក្សារបស់ព្រះអយ្យកោصلى الله عليه وآله وسلمព្រះអង្គصلوات الله عليه والسلامអស់ប្រាំមួយឆ្នាំ។ ព្រះអង្គصلوات الله عليه والسلامបានសិក្សាសីលធម៌ពីព្រះសាស្តាចុងក្រោយបង្អស់។ លុះព្រះអយ្យកោصلى الله عليه وآله وسلمព្រះអង្គصلوات الله عليه والسلامបានចូលទិវង្គត ព្រះអង្គصلوات الله عليه والسلامបានជ្រកក្រោមម្លប់ព្រះបិតាព្រះអង្គصلوات الله عليه والسلام អ៊ីម៉ាំអ៊ុាលីصلوات الله عليه والسلام អស់រយៈពេលសាមសិបឆ្នាំ។

នៅក្នុងរយៈពេលសាមសិបឆ្នាំនេះ ព្រះអង្គصلوات الله عليه والسلامនិងព្រះបិតាព្រះអង្គصلوات الله عليه والسلامបានអត់ទ្រាំចំពោះអំពើអយុត្តិធម៌ពីសំណាក់មុស្លីម និងបានចូលរួមក្នុងការលះបង់យ៉ាងសម្បើមដើម្បីរក្សាឯកភាពសហគមន៍មុស្លីម។

លុះព្រះបិតាصلوات الله عليه والسلامព្រះអង្គصلوات الله عليه والسلامបានឡើងកាន់អំណាច និងត្រូវជ្រើសជាខ៏លិហ្វដោយសំណាក់មុស្លីម ព្រះអង្គصلوات الله عليه والسلامបានចូលរួមប្រយុទ្ធជាមួយព្រះអង្គصلوات الله عليه والسلامក្នុងគ្រប់សមរភូមិ។

បន្ទាប់ពីព្រះរាជអគ្គមហាប្រមុខរបស់បណ្តាអ្នកមានសទ្ធាជ្រះថ្លាបានពលីជីវិត អាល់-ហ៊ូសែន៍صلوات الله عليه والسلامបាន សច្ចាប្រណិធានស្វាមីភ័ក្តិចំពោះអ៊ីម៉ាំអាល់-ហាសាន់صلوات الله عليه والسلام ព្រះរៀមរបស់ព្រះអង្គصلوات الله عليه والسلام ហើយជួយជ្រោមជ្រែង ព្រះអង្គصلوات الله عليه والسلامទាំងស្រុង ក្នុងការទប់ទល់ការបះបោររបស់មូអាវីយ៉ាស់ដែលប៉ងបំផ្លាញប្រព័ន្ធរដ្ឋាភិបាលស្រប ច្បាប់ដើម្បីបង្កើតរបបផ្តាច់ការរបស់ត្រកូលបានី អ៊ូម៉ៃយ៉ាស់(بنو أمية)ជាជំនួស។

កាលអ៊ីម៉ាំអាល់-ហាសាន់صلوات الله عليه والسلامចាំបាច់ត្រូវធ្វើកិច្ចព្រមព្រៀងសន្តិភាពជាមួយបុគ្គលបះបោររូបនេះ និងផ្ទេរ អំណាចឲ្យទៅបុគ្គលនេះជាបណ្តោះអាសន្នសិននោះ អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامនៅតែស្មោះត្រង់ ដូចសព្វដង ចំពោះអ៊ីម៉ាំស្របច្បាប់ និងស្តាប់បង្គាប់ព្រះអង្គصلوات الله عليه والسلامលុះដល់ពេលពលីព្រះជន្ម។

## អ៊ីម៉ាំនិងអំណាចមូអាវីយ៉ាស្ទ

យើងបានដឹងស្រាប់ហើយថា អ៊ីម៉ាំអាល់-ហាសាន់صلوات الله عليه والسلامត្រូវគេធ្វើគត់តាមបញ្ជារបស់មូអាវីយ៉ាស់ដែល មានបំណង តាមរយៈបទឧក្រិដ្ឋនេះ បង្កើតនូវមោឃស្មារតីនិងមោឃនិយោបាយដើម្បីងាយស្រួលតែងតាំង យ៉ាស៊ីដ្ទ កូនរបស់ខ្លួន ជាអ្នកស្នងខ្លួន។

អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامបានឡើងកាន់អំណាចដឹកនាំសាសនាស្របច្បាប់ (អ៊ីម៉ាម៉ាស់) ជួសអ៊ីម៉ាំអាល់-ហាសាន់صلوات الله عليه والسلام។ យោលតាមលក្ខណ្ឌនៃការយល់ព្រមធ្វើកិច្ចព្រមព្រៀងសន្តិភាពចុះហត្ថលេខារវាងមូអាវីយ៉ាស់ និងអ៊ីម៉ាំអាល់-ហាសាន់صلوات الله عليه والسلامនោះ អ៊ីម៉ាំហ៊ូសែន៍صلوات الله عليه والسلامត្រូវស្នងមូអាវីយ៉ាស់ក្រោយពីអ៊ីម៉ាំអាល់-ហាសាន់صلوات الله عليه والسلام ចូលទិវង្គត ហើយអំណាចនិយោបាយក៏ត្រូវផ្ទេរដោយស្របច្បាប់ដូច្នេះដែរ។

តែមូអាវីយ៉ាស់និងសំណាក់អ៊ូម៉ៃយ៉ាស់មិនចូលចិត្តបែបនេះទេ។ ពួកគេមិនព្រមបោះបង់អំណាចដោយ ងាយៗនោះទេ អំណាចដែលពួកគេបានពុះពារដណ្តើមយកបានមកដោយកលល្បិច ដោយឃាតកម្មនិងដោយ សំណូកសូកប៉ាន់។

ម្យ៉ាងទៀត ពួកអ៊ូម៉ៃយ៉ាស់ភាគច្រើនបានចូលសាសនាអ៊ីស្លាមដោយមានពុតត្បុត។ គេបានដឹងយ៉ាង ច្បាស់ស្រាប់ហើយថាជីតារបស់ពួកគេ អាប៊ូ ស៊ុហ្វយ៉ាន បានបែរមកកាន់សាសនារប់សអល់ឡោះហ្ទ៍عز وجلនៅ ពេលណា។ គេមិនបានភ្លេចឡើយថាគាត់មានប្រតិកម្មយ៉ាងណាខ្លះពេលដែលអំណាចបានធ្លាក់ទៅក្នុងដៃបានី អ៊ូម៉ៃយ៉ាស់ដោយសារអ៊ុស្មម៉ាន ខ៉ិលិហ្វទីបី។

តើគេសង្ឃឹមអ្វីខ្លះពីមូអាវីយ៉ាស់និងសំណាក់អ៊ូម៉ៃយ៉ាស់? មិនលើសពីអ្វីដែលប្រវត្តិសាស្ត្របានលើកឡើង ឲ្យយើងដឹងនោះទេ គឺ៖ ការកាប់សម្លាប់បងប្អូនមុស្លីមដែលនៅតែស្រឡាញ់ស្មោះត្រង់ចំពោះភាពសមស្របត្រឹម ត្រូវតាមច្បាប់ និងយុទ្ធការឃោសនាដើម្បីមើលងាយមើលថោកអ៊ីម៉ាំអាលីصلوات الله عليه والسلامនិងព្រះរាជកុលដ្ឋានعليهم السلامព្រះ អង្គصلوات الله عليه والسلام ហើយមិនត្រឹមតែប៉ុណ្ណោះទេ។

ពិតណាស់ មូអាវីយ៉ាស់ បុគ្គលប្រមាថសាសនា បានប្រព្រឹត្តដល់ថ្នាក់ហ៊ានបំភ្លៃពិធីធ្វើសក្ការៈរបស់បងប្អូន មុស្លីមដោយតម្រូវឲ្យមានការដាក់បណ្តាសានិងការជេរប្រទេចទៅលើអ៊ីម៉ាំអាលីصلوات الله عليه والسلام។ ឯពួកមុស្លីមល្ងង់ខ្លៅ អ្នកស្រុកប្រទេសស៊ីរីនិងតំបន់ដែលត្រូវបញ្ចូលសានសាអ៊ីស្លាមថ្មីៗនោះ ព្រមទទួលអំពើទាំងនេះឥតប្រកែក ដោយគិតថាអល់ឡោះហ្ទ៍عز وجلនឹងមិនទទួលការធ្វើសក្ការៈបូជារបស់ពួកគេទេបើពួកគេមិនសូត្របមន្តនេះ។

មុស្លីមដ៏តិចដែលតស៊ូនឹងអំណាចអយុត្តិធម៌របស់មូអាវីយ៉ាស់ និងដែលមិនព្រមថារូបមន្តជេរប្រទេចអាលី صلوات الله عليه والسلام ព្រះអគ្គមហាប្រមុខរបស់បណ្ដាអ្នកមានសទ្ធាជ្រះថ្លានោះ ត្រូវមូអាវីយ៉ាស់សម្លាប់។ ចំណែកឯសាវកភ័ក្ដីរបស់ព្រះសាស្ដាﷺក៏ចៀសមិនផុតដែរ។ ប្រវត្តិសាស្ត្របានចែងថា សាវកភ័ក្ដីម្នាក់របស់ព្រះអង្គﷺ ឈ្មោះហ៊ុច្ររី អ៊ីបនូ អាឌី(حجر بن عدي) និងកនប្រាំពីរនាក់របស់លោកត្រូវមូអាយ៉ាស់សម្លាប់នៅឯម៉ារយ៉ា អាស់រ៉ ក្បែរស្រុកដាម៉ាស់ ប្រទេសស៊ីរី។ បទឧក្រិដ្ឋរបស់វរជនទាំងនេះគឺមិនព្រមជេរប្រទេចអ៊ីមុាំអាលី صلوات الله عليه والسلام ។



យ៉ាស៊ីដ្ ដែលមូអាវីយ៉ាស់ប៉ងតែងតាំងជាអង្គម្ចាស់ស្នងរាជជួសខ្លួននោះ ជាបុរសកំណាចដែលមិនស្គាល់ច្បាប់ ហើយបានប្រព្រឹត្តអំពើទាំងអស់ដែលសាសនាអ៊ីស្លាមហាម គឺៈ ផឹកទាល់តែស្រវឹងជោកជាំ សេពគប់ជាមួយស្ត្រីដែលត្រូវហាម ចំណាយពេលមួយចំនួនធំដើម្បីបរបាញ់សត្វ និងលេងសប្បាយជាមួយសត្វស្វា។

អ៊ីមុាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام បានរំលឹកមូអាវីយ៉ាស់អំពីកំហុសដ៏ធ្ងន់ធ្ងររបស់ខ្លួន និងអំពីផលវិបាកដែលជះ

មកលើសហាគមន៍អ៊ីស្លាមទាំងមូល។ តែបុគ្គលប្រើអំណាចផ្តាច់ការរូបនេះមិនអើពើចំពោះប្រយោជន៍របស់សាសនាអ៊ីស្លាមនិងពួកមុស្លីមបន្តិចទេ ហើយបានសម្រេចចិត្តអនុវត្តតាមផែនការរបស់ខ្លួន។



ដូច្នេះ នៅក្រោមការគំរាមកំហែងដោយផ្លែដាវ ឥស្សរជនទាំងអស់និងកុលបុត្រនៃត្រកូលធំៗ ព្រមទាំងបណ្តាសាវកមួយចំនួនតូចរបស់ព្រះសាស្តា ﷺ ដែលមានជីវិតនៅឡើយ ត្រូវគេបង្ខំឲ្យសច្ចាចំពោះមូអាវីយ៉ាស់ថានឹងជួយជ្រោមជ្រែងយ៉ាស៊ីដ កូនប្រុសរបស់ខ្លួន ជាអ្នកស្នងខ្លួន។

## ២-អាល់-ហ៊ូសែន៍ صلوات الله عليه والسلام អ្នកសង្គ្រោះសាសនាអ៊ីស្លាម

# ប្រឈមនឹងយ៉ាស៊ីដ្ទ

លុះមូអាវីយ៉ាស់ស្លាប់ភ្លាម យ៉ាស៊ីដ្ទ កូនរបស់មូអាវីយ៉ាស់បានឡើងកាន់អំណាចនៅឯស្រុកដ្វាម៉ាស់គាំទ្រដោយត្រកូលបានី អ៊ូម៉ៃយ៉ាស់។ តែពិភពអ៊ីស្លាមទាំងអស់មិនអាចទទួលយកបានការស្នងតំណែងនេះទេ។ ដូច្នេះហើយបានជាយ៉ាស៊ីដ្ទប៉ងពង្រឹងមូលដ្ឋានខ្លួន ដោយព្យាយាមធ្វើឲ្យស្ថានភាពរបស់ខ្លួននោះទៅជាស្របតាមច្បាប់ ដោយការគាំទ្របុយ៉ាងហោចណាស់ដោយការនៅស្ងៀមរបស់អ៊ីម៉ុាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلام។

លុះបានឡើងកាន់អំណាចភ្លាម យ៉ាស៊ីដ្ទបានបញ្ជាអភិបាលអ៊ូម៉ៃយ៉ាស់នៃនគរម៉ាឌីណាស់ដោយបញ្ជាតឹងរ៉ឹងឲ្យបង្ខំអ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلامឲ្យសច្ចាស្មោះស្ម័គ្រនិងស្តាប់បង្គាប់(បៃអាស់ بَيْعَة)យ៉ាស៊ីដ្ទ។ តែអ៊ីម៉ុាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلامបានបដិសេធដាច់ខាតដោយកាត់ទោសយ៉ាស៊ីដ្ទដោយចេញមុខ កាត់ផ្តាច់យ៉ាស៊ីដ្ទឧពីពំនាក់ត្រឹមត្រូវស្របច្បាប់តែម្តង។

ក្នុងចន្លោះពេលនោះ អ្នកស្រុកគូហ្វាស់ដែលទទួលរងការសង្កត់សង្កិនពីសំណាក់អ៊ូម៉ៃយ៉ាស់ សង្ឃឹមថាអំណាចនឹងធ្លាក់មកក្នុងភាពត្រឹមត្រូវស្របតាមច្បាប់វិញ។ លុះពួកគេបានដឹងថាអ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلامបានបដិសេធបៃអាស់របស់យ៉ាស៊ីដ្ទ ពួកគេបានផ្ញើលិខិតគាំទ្រមកព្រះអង្គصلوات الله عليه والسلام សូមអញ្ជើញព្រះមកកាន់គូហ្វាស់ដើម្បីស្តារខ៊ុលីហ្វាស់ស្របច្បាប់ឡើងវិញ។

អ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلامបានទទួលលិខិតគាំទ្រលើសពី ១២០០០ ច្បាប់។ លិខិតទាំងអស់បានសូមឲ្យព្រះអង្គصلوات الله عليه والسلامផ្តល់នូវកិត្តិយសដល់ស្រុកគូហ្វាស់ដោយព្រះវត្តមានព្រះអង្គصلوات الله عليه والسلام ដោយស្បថថានឹងស្តាប់បង្គាប់ព្រះអង្គصلوات الله عليه والسلامទាំងស្រុង ហើយនឹងមិនទទួលស្គាល់អ៊ីម៉ាំផ្សេងពីព្រះអង្គصلوات الله عليه والسلامឡើយ។ អ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلامបានសម្រេចចិត្តចាត់បញ្ជូនសាវកជំនិតរបស់ព្រះអង្គ ដែលជាបងប្អូនជីដូនមួយព្រះអង្គصلوات الله عليه والسلامឈ្មោះមុស្លីម អ៊ីបនូ អាគ៊ីល ទៅជួបពួកគេដើម្បីពិនិត្យស្ថានការណ៍។

# មុស្លីមប្រឈមនឹងអ៊ីបនូ ស៊ីយ៉ាដ្ទ

លុះមុស្លីមបានមកដល់គូហ្វាស់ អ្នកស្រុកបានទទួលលោកយ៉ាងអធឹកអធម។ ពួកគេប្រញាប់ប្រញាល់សច្ចាស្មោះស្ម័គ្រភ័ក្តី និងអន្ទះអន្ទែងចង់ឃើញអ៊ីម៉ាំស្របច្បាប់ អ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلام។

មុស្លីមបានប្រាប់ពួកគេថាត្រូវតែមានសមត្ថភាពទទួលខុសត្រូវ ត្រូវត្រៀមខ្លួនការពារអ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلام ហើយត្រូវត្រៀមខ្លួនបូជាជីវិតដើម្បីព្រះអង្គصلوات الله عليه والسلام។

អ្នកស្រុកគូហ្វាស់ ១៨០០០ នាក់បានស្បថយ៉ាងម៉ឺងម៉ាត់ចំពោះព្រះអង្គصلوات الله عليه والسلام។ មុស្លីមបានផ្ញើរបាយការណ៍អំពីករណីទាំងអស់នេះផ្ញើទៅឲ្យអ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلام សូមឲ្យព្រះអង្គصلوات الله عليه والسلامយាងមក។

ក្នុងរយៈពេលនេះ យ៉ាស៊ីដ្ទបានចាត់បញ្ជូនមកកាន់គូហ្វាស់កូនរបស់អតីតអភិបាលស្រុករបស់គេ ដែលមានឈ្មោះថា អ៊ូបៃឌុលឡោះហ៍ អ៊ីបនូ ស៊ីយ៉ាដ្ទ (عبيد الله بن زياد) ដែលអាក្រក់និងសាហាវជាងឪពុកគេទៅទៀត។ យ៉ាស៊ីដ្ទបានបញ្ជាឲ្យអ៊ូបៃឌុលឡោះហ៍ អ៊ីបនូ ស៊ីយ៉ាដ្ទកាប់សម្លាប់បណ្តាអ្នកគាំទ្រអ៊ីម៉ាំអាល់-ហ៊ូសៃន៍

صلوات الله عليه والسلام និងឲ្យបង្រ្កាបការបះបោរនាស្រុកគូហ្វាស់។



ដើម្បីប្រតិបត្តិតាមបទបញ្ជារបស់យ៉ាស៊ីដ្ទ អ៊ូបៃឌុលឡោះហ៍ អ៊ីបនូ ស៊ីយ៉ាដ្ទ៍មិនត្រូវការភ្នាក់ងារលើសពីពីរបីនាក់និងប្រាក់មួយចំនួនធំទេ។ លុះបានចូលដល់ក្នុងស្រុកភ្លាម អ៊ូបៃឌុលឡោះហ៍ អ៊ីបនូ ស៊ីយ៉ាដ្ទ៍បានចាត់បញ្ជូនចារបុរសរបស់គេទៅក្នុងចំណោមពួកអ្នកស្រុកដើម្បីសាបព្រោះព័ត៌មានមិនពិត ថាកងទ័ពដ៏ធំរបស់យ៉ាស៊ីដ្ទកំពុងតែប្រុងវាយលុកស្រុកគូហ្វាស់។

ទន្ទឹមនឹងនេះដែរ អ៊ូបៃឌុលឡោះហ៍ អ៊ីបនូ ស៊ីយ៉ាដ្ទ៍បានសូកប៉ាន់ពួកមេដឹកនាំកុលសម្ព័ន្ធរបស់ស្រុកគូហ្វាស់។ អស់រយៈពេលតែពីរបីថ្ងៃប៉ុណ្ណោះ ស្រុកទាំងមូលបានផ្លាស់ប្តូរភាគី ទៅចូលខាងគេវិញ។

មុស្លីមមានបក្សពួកតិចទៅៗ ហើយយល់ថាមិនអាចពឹងពាក់លើពួកអ្នកស្រុកគូហ្វាស់បានទេ។ លោកប៉ងប្រាប់ឲ្យអ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامជ្រាបមុនព្រះអង្គصلوات الله عليه والسلامយាងមកកាន់ទីនេះ។

យោធារបស់អ៊ីបនូ ស៊ីយ៉ាដ្ធបានស្វែងរកមុស្លីម។ លោកបានតស៊ូយ៉ាងអង់អាចមុននឹងត្រូវរបួស ហើយត្រូវចាប់ខ្លួនទៅប្រគល់ឲ្យអភិបាលស្រុក។ អភិបាលស្រុកបានបញ្ជាឲ្យប្រហារជីវិតលោក។

ការពិត អវសានដ៏ខ្លោចផ្សារបស់មុស្លីមជាការចាប់ផ្ដើមរបស់សោកនាដកម្មដ៏ធំមួយ។ អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامបានត្រៀមខ្លួនជាស្រេចចំពោះសោកនាដកម្មនេះ។ ទោះជាបានទទួលដំណឹងមិនល្អពីគូហ្វាស់ក៏ដោយ ក៏អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامសម្រេចចិត្តចេញទៅប្រឈមវាសនាព្រះអង្គصلوات الله عليه والسلام ដើម្បីសង្គ្រោះសាសនាអ៊ីស្លាមឲ្យចាកផុតពីការប៉ុនប៉ងបំភ្លៃប្រកបដោយគ្រោះថ្នាក់ដែលពុំធ្លាប់បានជួបប្រទះកាលពីមុនមកឡើយ។

## អ៊ីម៉ាំធ្វើដំណើរទៅកាន់ការបាឡាអ៍(كربلاء)

ដំណឹងពលីកម្មជីវិតរបស់មុស្លីមនិងបក្សពួកលោកបានមកដល់អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلام ខណៈព្រះអង្គصلوات الله عليه والسلامកំពុងធ្វើដំណើរទៅកាន់គូហ្វាស់។ ព្រះអង្គصلوات الله عليه والسلامបានប្រាប់បណ្ដាអ្នកអមព្រះអង្គថា៖

*អ្នកណាទៅជាមួយយើង អ្នកនោះឆ្ពោះទៅរកទុក្ករៈកម្ម(ពលីកម្មជីវិតដើម្បីជំនឿខ្លួន)។ អ្នកណាចោលយើង អ្នកនោះពុំបានទទួលជ័យជំនះទេ។*

អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامជ្រាបច្បាស់នូវទិសដៅព្រះអង្គصلوات الله عليه والسلام។ ព្រះអង្គصلوات الله عليه والسلامចង់ឲ្យបណ្ដាអ្នកដែលតាមព្រះអង្គصلوات الله عليه والسلامនោះដឹងនូវទិសដៅនេះ គឺ៖ ព្រះអង្គصلوات الله عليه والسلامទៅនេះ មិនមែនក្នុងឋានៈជាអ្នកប្រយុទ្ធយកឈ្នះ ហើយក៏មិនមែនក្នុងឋានៈជាអ្នករត់គេចខ្លួនទេ តែព្រះអង្គصلوات الله عليه والسلامឆ្ពោះទៅរកពលីទុក្ករៈកម្ម។

ដោយវិធីនេះឯងដែលអ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامបានសម្រេចចិត្តធ្វើពលីកម្មជីវិត ដើម្បីដាស់សតិអារម្មណ៍សហគមន៍មុស្លីម សហគមន៍មុស្លីមដែលសំណាក់អ៊ូម៉ៃយ៉ាស់បានថ្នាក់ថ្នមបបោសអង្អែលតាំងពីម្ភៃឆ្នាំមកហើយ។ សហគមន៍មុស្លីមបានដេកលង់លក់ជ្រុលពេក ទាល់តែបង្ហូរឈាមព្រះរាជនត្តាصلوات الله عليه والسلامរបស់ព្រះសាស្ដាصلى الله عليه وآله وسلمទើបភ្ញាក់ពីដំណេកបាន។

មែនហើយ ទាល់តែអាល់-ហ៊ូសែន៍ ព្រះរាជបុត្រصلوات الله عليه والسلامរបស់ហ្វាទីម៉ាស់ អាស់ស្សាស់រ៉ស៍(فاطمة الزهراء) ព្រះនត្តាصلوات الله عليه والسلامរបស់មូហាំម៉ាដ្ធصلى الله عليه وآله وسلم ព្រះសាស្ដាចុងក្រោយបង្អស់ ត្រូវបនលាក់ពុតត្បុត គឺបនដែលប្រកាសខ្លួនថាជាអ៊ីស្លាមនោះធ្វើគត់ទើបមុខពិតរបស់ពួកអ៊ូម៉ៃយ៉ាស់ត្រូវបើកឡើងឲ្យឃើញច្បាស់។ មេរៀនទាំងអស់មិននៅត្រង់នេះទេ។



## គោលដៅរបស់អ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام

អាល់-ហ៊ូសៃន៍ صلوات الله عليه والسلام បានពន្យល់ដោយព្រះអង្គ صلوات الله عليه والسلام ផ្ទាល់ អំពីសកម្មភាពព្រះអង្គ صلوات الله عليه والسلام ចំណុចខ្លះប្រាប់ប្អូនប្រុសព្រះអង្គ صلوات الله عليه والسلام ឈ្មោះមូហាំម៉ាដ៌ អ៊ីបនូ អាល់-ហាណាហ្វីយ៉ាស់(محمد بن الحنفية)ថា៖

*ខ្ញុំ صلوات الله والسلام មិនចេញទៅក្នុងឋានៈជាបុគ្គលទុច្ចរិត ឬក្នុងឋានៈជាបុគ្គលប្រព្រឹត្តកន្លងករណីយកិច្ចខ្លួនទេ តែក្នុងឋានៈជាបុគ្គលដែលស្វែងរកនូវការកែតម្រង់ក្នុងសហគមន៍របស់ព្រះអយ្យកោ صلى الله عليه وآله وسلم របស់ខ្ញុំ صلوات الله والسلام ។ ខ្ញុំ صلوات الله والسلام ចង់*

*ឲ្យមាននូវភាពត្រឹមត្រូវ កម្ចាត់អំពើដែលនាំមកនូវការស្តីបន្ទោស និងដើរតាមគន្លងព្រះអយ្យកោ(عليهم السلام)ខ្ញុំ(صلوات الله والسلام) និងព្រះបិតា(صلوات الله والسلام)ខ្ញុំ(صلوات الله والسلام) អ៊ាលី(صلوات الله والسلام) ប៊ិន អាប៊ូ តូ៏លិបឪឆ ។*

អ៊ីម៉ាំបានអធិប្បាយសង្ខេបបេសកកម្មព្រះអង្គ(صلوات الله عليه والسلام)ដូចតទៅគឺ៖ ធ្វើឲ្យសាសនាអ៊ីស្លាមមានដូចដើមវិញនូវលក្ខណៈសង្គមកិច្ចនិងលក្ខណៈនិយោបាយដែលសំណាក់អ៊ូម៉ៃយ៉ាស់បានបំបិទចោល និងមានបំណងទុកសាសនាអ៊ីស្លាមជាឈុតពិធីដែលមានលក្ខណៈដាច់ឡែក មិនមានលទ្ធផលទៅលើវិស័យសង្គមកិច្ចនិងវិស័យនិយោបាយទេ បើកដៃឲ្យបុគ្គលទុច្ចរិតដែលកាន់អំណាចនោះធ្វើអ្វីតាមតែក្បាលចិត្ត។

សាសនាអ៊ីស្លាមត្រូវគំរាមដោយគ្រោះថ្នាក់តែមួយ គឺគ្រោះថ្នាក់ដែលបានបំបែរគ្រិស្តបរិស័ទពីសាសនារបស់អ៊ីសា(عليه السلام)។ ការបះបោររបស់អ៊ីម៉ាំអាល់-ហ៊ូសែន៍(صلوات الله عليه والسلام)បានបញ្ចប់ការបំភ្លៃដ៏ធំសម្បើមដែលមូអាវីយ៉ាស់បានចាប់ផ្តើម ហើយយ៉ាស៊ីដ្ធមានបំណងធ្វើឲ្យបានសម្រេចជាស្ថាពរ។

## **អាស៊ូរ៉អ៊ុ៍**(عاشوراء)

ទ័ពរបស់យ៉ាស៊ីដ្ធបានកាក់ក្បួនទូរចររបស់អ៊ីម៉ាំអាល់-ហ៊ូសែន៍(صلوات الله عليه والسلام) នៅឯកន្លែងមួយដែលហៅថាការបាឡាអ៊ុំក្បែរព្រៃកមួយរបស់ស្ទឹងហ្វ៊ូរ៉ត(الفرات)។ ទ័ពរបស់យ៉ាស៊ីដ្ធបានកាក់រវាងក្បួនទូរចររបស់អ៊ីម៉ាំអាល់-ហ៊ូសែន៍និងទឹកស្ទឹង ដើម្បីបង្អត់ទឹកស្រីៗនិងក្មេងៗនៅកណ្តាលថ្ងៃក្តៅហែង។

ថ្ងៃសុក្រទី ១០ ខែមូហារ៉ម ឆ្នាំ ៦១ សករាជហ៊ីជ្រ៉ោះត៍ លុះបានអត់ទឹកអស់បីថ្ងៃ អ៊ីម៉ាំអាល់-ហ៊ូសែន៍(صلوات الله عليه والسلام)បានប្រមូលបក្សពួកភ័ក្តិ ៧២ នាក់មកប្រាប់ថាឲ្យត្រៀមខ្លួនបូជាជីវិត។ បន្ទាប់ពីនោះព្រះអង្គ(صلوات الله عليه والسلام)បានយាងទៅរកទ័ពភាគីលាក់ពុតដើម្បីរំលឹកពួកគេឲ្យភ្ញាក់រលឹកស្មារតីនិងដឹងកំហុស ដាស់តឿនពួកគេថាព្រះអង្គ(صلوات الله عليه والسلام)ជាព្រះនត្តា(صلوات الله عليه والسلام)របស់ព្រះសាស្តា(صلى الله عليه وآله وسلم) និងបានប្រកាសប្រាប់ពួកគេថាពួកគេត្រូវហាមបង្ហូរឈាមព្រះអង្គ(صلوات الله عليه والسلام)។ ព្រះអង្គ(صلوات الله عليه والسلام)រំលឹកពួកគេដែរថាព្រះសាស្តា(عليهم السلام)ធ្លាប់មានព្រះវចនៈថា៖ "អាល់-ហាសាន់(صلوات الله عليه والسلام)និងអាល់-ហ៊ូសែន៍(صلوات الله عليه والسلام)ជាព្រះបរមគ្រូរបស់យុវជនឋានសួគ៌។"

ការពិត ទ័ពរបស់យ៉ាស៊ីដ្ធសុទ្ធតែពួកអ្នកស្រុកគូហ្វាស់(الكوفة)ដែលអ៊ូបៃឌុលឡោះហ៍ អ៊ីបនូ ស៊ីយ៉ាដ្ធបានសូកប៉ាន់។ ពួកមេដឹកនាំពួកគេភាគច្រើនគឺពួកដែលបានផ្ញើលិខិតទៅអ៊ីម៉ាំអាល់-ហ៊ូសែន៍(صلوات الله عليه والسلام) សូមអញ្ជើញព្រះអង្គ(صلوات الله عليه والسلام)យាងមកកាន់គូហ្វាស់។

ដូច្នេះហើយបានជាព្រះវចនៈអ៊ីម៉ាំអាល់-ហ៊ូសែន៍(صلوات الله عليه والسلام)ពុំមានប្រសិទ្ធិភាពលើពួកគេទេ។ នៅចំពោះមុខព្រះអង្គ(صلوات الله عليه والسلام)មានតែពួកអសទ្ធាដែលបានលក់ដួងវិញ្ញាណឲ្យបិសាច។

ចម្លើយរបស់ពួកពុតត្បុតទាំងនេះគឺ៖ "ចូរសច្ចាភ័ក្តិ(បៃអ៊ាស់)ចំពោះយ៉ាស៊ីដ្ធដូចយើងដែរទៅ!" តែអ៊ីម៉ាំអាល់-ហ៊ូសែន៍(صلوات الله عليه والسلام)បានបះបោរប្រឆាំងទង្វើនេះឯង។ ព្រះអង្គ(صلوات الله عليه والسلام)ឆ្លើយតបពួកគេវិញយ៉ាងម៉ឹងម៉ាត់ថាមនុស្សមិនគប្បីន្ទោកខ្លួនដើម្បីជីវិតនោះទេ ស្លាប់បង្គាប់បុគ្គលទុច្ចរិតដូចយ៉ាស៊ីដ្ធជាសេចក្តីថោកទាបដែលមិនអាចទទួលយកបានឡើយសម្រាប់មនុស្សគ្រប់រូបដែលមានសេរីភាព សាសនាអ៊ីស្លាមហាមធ្វើបែបនេះ។

អ៊ុំម៉ារ ប៊ិន សាអ៊ីដ្ន មេទ័ពរបស់យ៉ាស៊ីដ្ន បានបញ្ជាឲ្យចូលប្រយុទ្ធ។ នេះគឺសមរភូមិដ៏ធំមួយរវាងក្រុមសាវក ដ៏តូចមួយរបស់អ៊ីមុាំអាល់-ហ៊ុសែន៍صلوات الله عليه والسلامនិងទ័ពដ៏ធំរបស់យ៉ាស៊ីដ្នដែលមានចំនួនរាប់ពាន់នាក់។

បន្ទាប់ពីបានប្រយុទ្ធយ៉ាងអង់អាចក្លាហាន កងទ័ពបានដកថយដោយបាត់បង់រេហ៍ពលច្រើន។ ចំណែកឯ បណ្តាសាវកអ៊ីមុាំصلوات الله عليه والسلامវិញបានបាត់បង់បក្សពួកភ័ក្តីចំនួនហាសិបនាក់។



ការប្រយុទ្ធបានបន្តទៅមុខទៀតក្នុងលក្ខណៈផ្ទាល់ខ្លួន៖ ម្តងម្នាក់ៗ សាវកនិងជំនិតរបស់អ៊ីមុាំصلوات الله عليه والسلامបាន ចូលទៅក្នុងលានប្រយុទ្ធ វាយប្រហារទ័ពសត្រូវដើម្បីបំពេញទុក្ករៈកម្ម។ ពួកគេអន្ទះសាទៅតាមបងប្អូនពួកគេ នៅឯឋានសួគ៌។

បើគេចង់ថ្លែងអំពីសេចក្ដីក្លាហាន និងសេចក្ដីថ្លៃថ្នូររបស់បក្សពួកភ័ក្ដីរបស់អ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام នាថ្ងៃនោះ ពិតណាស់ គេអាចលើកយកប្រវត្តិរបស់អ៊ាប់បាស់ ប្អូនប្រុសរបស់អ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام ដែលជាប្រវត្តិដ៏ប្រសើរបំផុតមកពិពណ៌នាអធិប្បាយបាន គឺ៖



អ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام បានឲ្យលោកទៅយកទឹកមកឲ្យក្មេងៗដែលស្រេកទឹកស្ទើរស្លាប់។ លោកបានវាយប្រហារទម្លាយក្រុមការពារដែលនៅចន្លោះពួកគេនិងស្ទឹងលុះបានទៅដល់មាត់ស្ទឹង។ លោកបានបំពេញថង់ទឹក។ លោកប៉ុនប៉ងផឹកទឹក តែលោកបាននឹកឃើញទាន់ថាអ៊ីម៉ាំ صلوات الله عليه والسلام មិនអាចសោយទឹកបានដូចលោក

ពេលនេះទេ។ លោកក៏ខំអត់ទ្រាំ និងប្រញាប់យកទឹកទៅជំរំវិញ តែត្រូវគេធ្វើឃាតតាមផ្លូវ ដោយឥតអាចផឹកទឹកបានឡើយបន្ទាប់ពីបានស្រេកទឹកអស់បីថ្ងៃ។

ក្រោយពីបក្សពួកទាំងអស់របស់ព្រះអង្គ صلوات الله عليه والسلام ត្រូវកាប់សម្លាប់ អ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام បានលាបណ្តាស្ត្រី និងក្មេងៗ សូមឲ្យពួកគេអត់ទ្រាំវាសនាដែលព្រះដ៏មហាខ្ពង់ខ្ពស់ عزّ وجلّ បានត្រៀមទុកសម្រាប់ពួកគេ រំលឹកពួកគេអំពីភាពថ្លៃថ្នូររបស់មូលហេតុពួកគេ។



បន្ទាប់ពីនោះ ព្រះអង្គ صلوات الله عليه والسلام បានចូលទៅក្នុងជំរំរបស់ព្រះរាជបុត្រព្រះអង្គ صلوات الله عليه والسلام អ៊ុាលី ស៊ែនុល-អ៊ុាប៊ីឌីន (علي زين العابدين) ដែលកំពុងឈឺមិនអាចចូលរួមក្នុងការប្រយុទ្ធបាន។ ព្រះអង្គ صلوات الله عليه والسلام ជាបុរសតែម្នាក់គត់ដែលរួច

ជីវិតពីការកាប់សម្លាប់នេះ។

អ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام បានសូមឲ្យព្រះអង្គ صلوات الله عليه والسلام រក្សានូវភាពស្ងប់ស្ងាត់ ទោះជាមានព្រឹត្តិការណ៍អ្វីកើតឡើងក៏ដោយ និងសូមឲ្យព្រះអង្គ صلوات الله عليه والسلام រក្សាជីវិតព្រះអង្គ صلوات الله عليه والسلام ជាចាំបាច់ដើម្បីបន្តស្នាដៃរបស់អ្នកមុនៗព្រះអង្គ صلوات الله عليه والسلام គឺ៖ ការពារជំនឿឲ្យគង់វង្ស បង្ហាត់បង្រៀនសិក្ខាបទអ៊ីស្លាម ការពារមូស្លីមកុំឲ្យវប្បធមិបរទេសរាតត្បាតមកលើបាន។

អ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام បានយាងទៅប្រឈបទ័ពពួកពុតត្បុត។ ទោះជាព្រះអង្គ صلوات الله عليه والسلام មិនប៉ិនប្រសប់លើសពីប្រក្រតីក្នុងការធ្វើសឹកក៏ដោយ តែការប្រយុទ្ធរបស់ព្រះអង្គ صلوات الله عليه والسلام ជាការប្រយុទ្ធអស្ចារ្យ។ រាល់គ្រាដែលព្រះអង្គ صلوات الله عليه والسلام វាយប្រហារក្រុមណាមួយ ក្រុមនោះវិនាសឬចុះចាញ់រត់ប្រាសអាយុ។

ទ័ពពួកពុតត្បុតបានរើសយកយុទ្ធការបាញ់គ្រាប់ព្រួញនិងចោលដុំថ្ម។ ព្រួញមួយបានទម្លុះកអ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام បណ្តាលឲ្យព្រះអង្គ صلوات الله عليه والسلام ធ្លាក់ពីលើខ្នងសេះ។ ពុំមានអ្នកណាហ៊ានចូលទៅជិតទេ។ ពួកគេទំនងជាដឹងខ្លួនថាបានប្រព្រឹត្តបទប្រមាថពិសិដ្ឋបុគ្គល ហើយពួកគេត្រូវទទួលរងព្រះពិរោធអល់ឡោះហ៍ عز وجل។ មានតែបុគ្គលអសទ្ធាអាក្រក់អន្យតិរ្ថិយចងគំនុំម្នាក់ទេ ឈ្មោះស៊ីមរ៍ ព្រឹទ្ធបាលជំនិតម្នាក់របស់អ៊ុបៃឌុលឡោះហ៍ អ៊ិបនូស៊ីយ៉ាដ្ធ ដែលហ៊ានធ្វើតាមបញ្ជារបស់ចៅហ្វាយខ្លួន គឺ៖ កាត់ព្រះសិរអ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام ហើយដោតព្រះសិរព្រះអង្គ صلوات الله عليه والسلام នោះនៅលើចុងលំពែង។

សំណាក់អ៊ូម៉ៃយ៉ាស់គុំកួនឥតព្រំដែនមកលើអាស់លុលបៃត៍ عليهم السلام មកលើអ៊ីស្លាមនិងមកលើអ្វីដែលតាងសាសនាអ៊ីស្លាម។ ពិតណាស់ មេបញ្ជាការទ័ពយ៉ាស៊ីដ្ធមិនត្រឹមតែកាប់សម្លាប់ទេ ថែមទាំងបញ្ជាឲ្យពលសេះដប់នាក់ជាន់ឈ្លីសពឥតព្រះសិរអ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام។ បន្ទាប់ពីនោះបុគ្គលចិត្តអន្យតិរ្ថិយរូបនេះបានបញ្ជាដុតជំរំស្រ្តីនិងក្មេងៗ។

ស៊ៃណាប់ سلام الله عليها ព្រះអនុជរបស់អ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام បានហៅនិងបានរម្ងាប់អារម្មណ៍បណ្តាស្រ្តីនិងក្មេងៗដែលភ័យរន្ធត់ រត់រប៉ាត់រប៉ាយគ្រប់ទិសទី។ ប្រកបដោយសេចក្តីអង់អាចក្លាហានដែលគ្មានអ្នកណាមានក្រៅពីព្រះរាជនត្តារបស់ព្រះសាស្តា صلى الله عليه وآله وسلم ព្រះនាង سلام الله عليها បានយាងទៅលើកព្រះរាជសពអ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام ព្រះរៀម صلوات الله عليه والسلام របស់ព្រះនាង سلام الله عليها មកឱប លើកទៅឯមេឃហើយទូលថា៖ "អល់ឡោះហ៍ عز وجل អើយ សូមព្រះអង្គ عز وجل ទទួលពលីកម្មនេះពីអស់ទូលព្រះបង្គំជាខ្ញុំផង។"

# មេរៀនការបាឡាអ៍

ពិតណាស់ អ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام មិនចង់ដណ្តើមយកអំណាចដោយការបះបោរប្រឆាំងរបបផ្តាច់ការរបស់សំណាក់អ៊ូម៉ៃយ៉ាស់ទេ។ ប្រសិនបើព្រះអង្គ صلوات الله عليه والسلام មានគោលបំណងដូច្នេះមែននោះ ព្រះអង្គ صلوات الله عليه والسلام ប្រាកដជាបានដកថយទៅវិញ ពេលបានទទួលដំណឹងថាមូស្លីមត្រូវគេធ្វើឃាត ហើយពួកអ្នកស្រុកគូហ្វាស់បានក្បត់ព្រះអង្គ صلوات الله عليه والسلام នោះ។

អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامគ្រាន់តែចង់បង្ហាញមុស្លីមគ្រប់រូបនូវមាគ៌ាសេរីភាព គឺៈ មិនត្រូវធ្វើឲ្យអំណាចទុច្ចរិតទៅជាស្របច្បាប់ជាដាច់ខាត ទោះជាត្រូវលះបង់ជីវិតខ្លួនឯងក៏ដោយ។

អាស៊ូរ៉ អ៊ុំជាពាក្យអារ៉ាប់ក្លាយមកពីពាក្យអាស៊ូរ៍ដែលមានន័យថាដប់។ គឺដប់ថ្ងៃដំបូងរបស់ខែមូហារ៉មដែលសោកនាដកម្មនេះបានកើតឡើង ហើយដែលគេធ្វើពិធីរំលឹក។ រៀងរាល់ឆ្នាំ អ្នកស្រឡាញ់អាស់លុលបៃត៍عليهم السلامធ្វើពិធីរំលឹកទុក្ករៈកម្មរបស់អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلام ព្រះរាជអគ្គមហាប្រមុខរបស់ទុក្ករៈបុគ្គលទាំងឡាយ និងរបស់បក្សពួកភក្តីរបស់ព្រះអង្គصلوات الله عليه والسلامដែលបានបូជាជីវិតដើម្បីការពារអ៊ីស្លាមបរិសុទ្ធ។

មុនសោកនាដកម្មការបាឡាអ៊ុំ ថ្ងៃអាស៊ូរ៉អ៊ុំមិនមានអ្វីពិសេសពិសាលទេ តែចាប់តាំងពីពេលនោះមក ថ្ងៃអាស៊ូរ៉អ៊ុំជានិម្មិតសញ្ញានៃការតស៊ូប្រឆាំងរបបផ្តាច់ការ និងជានិមិត្តរូបរបស់បុគ្គលមានសេរីគ្រប់រូបដែលព្រមស្លាប់ជាជាងរស់នៅដោយគ្មានគោលសីលធម៌ខ្លួនឯង។

អាស៊ូរ៉អ៊ុំជាថ្ងៃរបស់មនុស្សមានសេរីភាពគ្រប់រូប។

អាស៊ូរ៉អ៊ុំជាថ្ងៃបុណ្យរបស់អ្នកបដិវត្តន៍គ្រប់រូបដែលស្វែងរកសមធម៌និងយុត្តិធម៌។

អាស៊ូរ៉អ៊ុំជាថ្ងៃធ្វើពលីកម្មដ៏ប្រសើរបំផុតដើម្បីសព្វព្រះហឫទ័យអល់ឡោះហ៍عز وجل។

## ៣-សីលធម៌របស់ព្រះរាជអគ្គមហាប្រមុខរបស់ទុក្ករៈបុគ្គលទាំងឡាយ

## នៅជុំជាមួយអល់ឡោះហ៍عز وجلគ្រប់ទិសទី

អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامនៅគ្រប់ទិសទីជាមួយអល់ឡោះហ៍عز وجلជានិច្ច។ ទោះជានៅក្នុងស្ថានភាពដុនដាបយ៉ាងណាក៏ដោយក៏ព្រះអង្គصلوات الله عليه والسلامមិនបែរចេញពីការប៉ុនប៉ងអចិន្ត្រៃយ៍នេះជាដាច់ខាតដែរ។

ដូច្នេះ ការបំពេញស្វ៊ឡាត៍នៅក្នុងពេលល្អបំផុតរបស់ស្វ៊ឡាត៍នោះសំខាន់លើសកិច្ចការផ្សេងៗទាំងអស់។ ឧទាហរណ៍ដែលគួរឲ្យចាប់អារម្មណ៍បំផុត ពាក់ព័ន្ធនឹងសារសំខាន់របស់ពេលស្វ៊ឡាត៍សម្រាប់អ៊ីម៉ាំصلوات الله عليه والسلامនោះគឺបានមកពីសោកនាដកម្មការបាឡាអ៊ុំតែម្តង។ ពិតណាស់ ខណៈដែលកំពុងប្រយុទ្ធយ៉ាងស្វិតស្វាញរវាងក្រុមបក្សពួកដ៏តូចរបស់អ៊ីម៉ាំصلوات الله عليه والسلامនិងទ័ពពួកពុតត្បុត ព្រះអង្គصلوات الله عليه والسلامបានសូមឲ្យប៊ិន សាអ៊ីដ្ឋបញ្ឈប់ការប្រយុទ្ធមួយរយៈសិនដើម្បីបំពេញស្វ៊ឡាត៍ពេលថ្ងៃ។ សំណូមពរនេះធ្វើឲ្យប៊ិន សាអ៊ីដ្ឋទើសទាល់ លោកមិនអាចបដិសេធបានទេព្រោះលោកអាចបាក់មុខចំពោះភាគីមុស្លីមក្នុងពិភពលោក លោកប្រាថ្នារក្សាអាការៈក្រៅរបស់សាសនាអ៊ីស្លាមរបស់លោក។ នៅទីបំផុតលោកក៏បានយល់ព្រម តែយល់ព្រមតែមាត់ទេ ព្រោះអ៊ីម៉ាំصلوات الله عليه والسلامនិងបក្សពួកព្រះអង្គصلوات الله عليه والسلامបានបំពេញស្វ៊ឡាត៍នៅក្រោមភ្លៀងគ្រាប់ព្រួញនិងដុំថ្ម។

អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامបានបន្សល់ទុកឲ្យយើងនូវការបួងសួងដ៏ល្បីល្បាញមួយ ដែលយកល្អឲ្យសូត្រនៅថ្ងៃអារ៉ាហ្វាស៍ (ថ្ងៃទី ៩ ស៊ុលហ៊ីច្ចយ៉ាស៍)។ នៅក្នុងវាចាបួងសួងនេះគេឃើញមាននូវសញ្ញាដ៏ច្បាស់បញ្ជាក់អំពីទស្សនៈរបស់ព្រះអង្គصلوات الله عليه والسلامស្តីអំពីវត្តមានអល់ឡោះហ៍عز وجل អំពីការស្តាយកំហុសពិតប្រាកដ និងអំពីទំនាក់ទំនងរវាងអ្នកគោរពបូជានិងអ្នកបង្កើត។

ម្យ៉ាងទៀត ព្រះអង្គصلوات الله عليه والسلامតូចចិត្តអំពីបណ្តាអ្នកដែលចង់បកស្រាយឲ្យដឹងថាមានអល់ឡោះហ៍عز وجلនោះ។

ព្រះអង្គصلوات الله عليه والسلامទូលអល់ឡោះហ៊ូعز وجلថា៖ "*តើព្រះអង្គصلوات الله والسلام អវត្តមានពេលណា ដែលបណ្តាលឲ្យគេព្យាយាមបកស្រាយឲ្យដឹងថាមានព្រះអង្គعز وجل,នោះ? សូមឲ្យវាខ្វាក់ទៅ ភ្នែកដែលមិនឃើញថាព្រះអង្គعز وجل,ជាព្រះដែលត្រួតត្រាលើវានោះ!*"

អ៊ីមុាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامរស់នៅជាបុគ្គលស្វែងសីលធម៌។ ព្រះអង្គصلوات الله عليه والسلامចង់ឲ្យអស់អ្នកតាមព្រះអង្គصلوات الله عليه والسلامយកគំរូតាមព្រះអង្គصلوات الله عليه والسلام។ ដូច្នេះ ដើម្បីគាប់ព្រះហឫទ័យអល់ឡោះហ៊ូعز وجلព្រះអង្គصلوات الله عليه والسلامបានធ្វើពិធីហាច្ច៍យ៉ុច្រើនដងដោយថ្មើជើង ទោះជាព្រះអង្គصلوات الله عليه والسلامមានសមត្ថភាពរកជំនិះដ៏ល្អបានក៏ដោយ។ តែព្រះអង្គصلوات الله عليه والسلامស្គាល់តម្លៃនៃការនឿយហត់នៅលើមាគ៌ាអល់ឡោះហ៊ូعز وجلច្បាស់ណាស់។ អ៊ីមុាំصلوات الله عليه والسلامអន្ទះសាចង់នឿយហត់ដើម្បីអល់ឡោះហ៊ូعز وجل, ក្នុងពេលរង់ចាំថ្ងៃការបាឡាអ៊ុំនោះ ដែលព្រះអង្គصلوات الله عليه والسلامនឹងបូជាព្រះជន្មដើម្បីសាសនាអ៊ីស្លាមដោយបានភ្លក្សនូវរសជាតិពលីទុក្ករៈកម្ម។



ដូច្នេះ ពិធីហ្វាច្យ៉ថ្មើជើងតាមផ្លូវវាលខ្សាច់ប្រាំមួយរយគីឡូម៉ែត្រជាការលួងចិត្តសម្រាប់ព្រះអង្គ صلوات الله عليه والسلام ក្នុងការរង់ចាំថ្ងៃអាស៊ូរ៉អ៊ុំដ៏ឧឡារិកនោះ។

## អ៊ីម៉ាំ صلوات الله عليه والسلام បម្រើជនទ័លក្រ



អ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام ជាមិត្តរបស់ជនក្រីក្រតោកយ៉ាកទាំងឡាយ។ ព្រះអង្គ صلوات الله عليه والسلام បានចែកចាយជំនួយនិងសទ្ធាទានដល់ពួកគេដោយលាក់បាំងក្នុងពេលយប់ មិនឲ្យពួកគេមើលស្គាល់ព្រះអង្គ صلوات الله عليه والسلام ទេ។ ទាល់តែនៅពេលបញ្ចុះសពព្រះអង្គ صلوات الله عليه والسلام ទើបមនុស្សម្នាបានដឹងរឿងពិតនេះ គឺពេលពួកគេបានឃើញមានស្លាក

ស្នាមនៅលើស្មានិងខ្នងព្រះអង្គ صلوات الله عليه والسلام បញ្ជាក់ថាព្រះអង្គ صلوات الله عليه والسلام បានលីសែងបន្ទុកធ្ងន់រៀងរាល់យប់។ ពួកគេបានសាកសួរព្រះរាជបុត្រព្រះអង្គ صلوات الله عليه والسلام  ស៊ែនុលអាប៊ីឌីន صلوات الله عليه والسلام អំពីដើមហេតុនៃស្លាកស្នាមទាំងនេះ។ ពួកគេក៏បានស្គាល់ជនទាំងអស់ដែលបានផ្តល់ស្បៀងនិងបានជួយសង្គ្រោះជនតោកយ៉ាកទាំងឡាយនៃនគរម៉ាឌីណាស់ដោយមិនឲ្យគេដឹង។



ថ្ងៃមួយអ៊ីម៉ាំអាល់-ហ៊ុសែន៍ صلوات الله عليه والسلام បានដើរជិតជនក្រីក្រតោកយ៉ាកដែលកំពុងតែបរិភោគនំបុាំងស្ងួត។  ពួកគេបានស្នើសូមឲ្យព្រះអង្គឌ៏ថចូលរួមបរិភោគអាហារដ៏តិចតួចជាមួយពួកគេ  ដោយសេចក្តីសប្បុរសនៃជនសាមញ្ញ។ ព្រះអង្គ صلوات الله عليه والسلام បានយល់ព្រមដោយពេញចិត្ត និងបានអង្គុយផ្ទាល់ដីជាមួយពួកគេ។

បរិភោគរួច ព្រះអង្គ صلوات الله عليه والسلام បានអញ្ជើញពួកគេទៅបរិភោគអាហារពេលល្ងាចនៅឯផ្ទះព្រះអង្គ صلوات الله عليه والسلام ថា៖ "ខ្ញុំ صلوات الله عليه والسلام បានទទួលការអញ្ជើញរបស់អស់លោក  ដូច្នេះសូមអស់លោកព្រមទទួលការអញ្ជើញរបស់ខ្ញុំ صلوات الله عليه والسلام វិញ

ម្ដង ។"

## ៤-លោហិតឈ្នះផ្លែងាវ

## ការរំលឹកថ្ងៃអាស៊្ហ៊ូរ៉អ៍

សំណាក់អ៊ូម៉ៃយ៉ាស់ព្យាយាមចាត់ទុកថ្ងៃអាស៊្ហ៊ូរ៉អ៍ជាថ្ងៃបុណ្យមួយ ព្រោះយោលតាមយ៉ាស៊ីដផ្ទាល់តែម្ដង ថ្ងៃនេះជាថ្ងៃសងសឹកដែលសំណាក់អ៊ូម៉ៃយ៉ាស់ចង់បានតាំងពីសមរភូមិបាដ្រ៍មកម្ល៉េះ។

តែការពិត ថ្ងៃអាស៊្ហ៊ូរ៉អ៍ជាថ្ងៃចង្រៃឧបទ្រពសម្រាប់សំណាក់អ៊ូម៉ៃយ៉ាស់ផ្ទាល់តែម្ដង គឺៈ ចាប់តាំងពីថ្ងៃនោះ រហូតដល់ចប់រជ្ជកាលអ៊ូម៉ៃយ៉ាស់ គេបានកត់ត្រាទុកថា យ៉ាងតិចមានបដិវត្តន៍មួយដងក្នុងមួយឆ្នាំ ហើយរបប



អ៊ូម៉ៃយ៉ាស់ជារបបដែលមិនចិតថេរជាងគេក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម។ យ៉ាស៊ីដផ្ទាល់បានស្លាប់បន្ទាប់ពីសោកនាដកម្មការបាឡាអ៍បន្តិច។ ប្រវត្តិសាស្ត្របានរៀបរាប់ឲ្យដឹងថាលោកត្រូវសត្វសាហាវស៊ី ឥតទាំងបានទទួលពិធីបុណ្យសព ឥតទាំងមានផ្នូរកប់ទៀតផង។

ទន្ទឹមនិងនេះ ព្រះចេតិយអ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام នៅឯការបាឡាអ៍ រហូតមកដល់សព្វថ្ងៃ ជាបូនីយដ្ឋានដ៏ពិសិដ្ឋបំផុតមួយនៅក្នុងពិភពលោកអ៊ីស្លាម។ មុស្លីមមកទស្សនៈព្រះបូជនីយដ្ឋាននេះ ពីទិសទាំងបួននៃពិភពលោក។ ចំណែកឯសំណាក់អ៊ូម៉ៃយ៉ាស់និងបណ្តាអ្នកស្នងអន្សត៌ិ្លយពួកគេនោះវិញគ្មានអ្នកណាចងចាំឡើយ។ ប្រសិនបើមុស្លីមនឹកឃើញពួកគេ គឺគ្រាន់តែនឹកឃើញឡើងដើម្បីដាក់បណ្តាសាពួកគេប៉ុណ្ណោះ។

ដរាបណាស្ថានភាពនិយោបាយផ្តល់ឱកាសឲ្យ ដរាបនោះមុស្លីមទាំងឡាយប្រញាប់ប្រញាល់ធ្វើពិធីរំលឹកថ្ងៃអ៊ាស៊ូរ៉អ៍។ នៅប្រទេសអេស៊ីបត៍ មានក្រមហ្វាទីមីយ៉ាស់(الفاطمية) នៅឯប្រទេសអ៊ីរ៉ង់និងប្រទេសឥណ្ឌៀមានក្រុមស៊ូលតួន ដៃឡាមី(ديلمي) បានធ្វើពិធីរំលឹកការបាឡាអ៍និងថ្ងៃអ៊ាស៊ូរ៉អ៍ដំបូងបង្អស់។

បន្តិចម្តងៗ ពិធីទាំងនេះបានរាយសុសសាយក្នុងចំណោមមុស្លីមដែលមានជោគវាសនាស្គាល់តម្លៃអាស់លុលបៃត៍ عليهم السلام។

ការរំលឹកថ្ងៃអ៊ាស៊ូរ៉អ៍មិនមានតម្លៃត្រឹមតែជានិមិត្តរូបទេ តែការរំលឹកថ្ងៃអ៊ាស៊ូរ៉អ៍ជាពិធីដែលដាស់យើងឲ្យនឹកឃើញនូវសារៈសំខាន់របស់សាសនាអ៊ីស្លាមគឺ៖ ការលះបង់ និងការបូជាខ្លួនដើម្បីគាប់ព្រះហឫទ័យអល់ឡោះហ៍ عز وجل។

## ជ័យជំនះរបស់អ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام

កុំគិតឡើយថាការកាប់សម្លាប់នៅឯការបាឡាអ៍ជាជ័យជំនះរបស់សំណាក់អ៊ូម៉ៃយ៉ាស់លើអាស់លុលបៃត៍ عليهم السلام តែការពិតគឺផ្ទុយពីនោះ៖ អ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام បានសម្រេចគ្រប់គោលដៅព្រះអង្គ صلوات الله عليه والسلام ចំណែកឯយ៉ាស៊ីដវិញបានទទួលតែរឿងអាស្រូវនិងអំណាចមិនចិតថេរ ហើយបន្ទាប់ពីនោះ នឹងត្រូវបណ្តាអ្នកមានសទ្ធាជ្រះថ្លាដាក់បណ្តាសារហូតដល់ថ្ងៃរស់ពីស្លាប់វិញ។

នាថ្ងៃអ៊ាស៊ូរ៉អ៍ អ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام ចង់បកស្រាយនូវច្បាប់ពិសិដ្ឋរបស់ព្រះគឺ៖ រាល់ពេលដែលមានការប្រយុទ្ធរវាងលោហិតនិងផ្លែដាវ លោហិតនឹងឈ្នះផ្លែដាវជាមិនខាន។

ច្បាប់នេះបានញ៉ាំងចិត្តគំនិតបណ្តាអ្នកបដិវត្តន៍មុស្លីមក្នុងទូទាំងប្រវត្តិសាស្ត្រ។

យើងអាចមើលឃើញថាច្បាប់នេះបានទៅជាពិតយ៉ាងសុក្រឹតឬមិនសូវសុក្រឹត នៅក្នុងការបះបោរនិងក្នុងបដិវត្តន៍ទាំងឡាយរបស់មហាជនដែលត្រូវសង្កត់សង្កិនប្រឆាំងបុគ្គលកាន់អំណាចផ្តាច់ការតូចធំ។




មិនមែនជារឿងចៃដន់ទេដែលប្រជារាស្ត្រអ៊ីរ៉ង់បានធ្វើឲ្យច្បាប់នេះទៅជាពិតយ៉ាងប្រសើរជាងគេនោះ។ ពិតណាស់ ក្នុងព្រះនាមអ៊ីមុាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام ដែលឈាមយុវជនអ៊ីរ៉ង់បានឈ្នះផ្លែដាវដែលមានអាយុកាលរាប់ពាន់ឆ្នាំរបស់ស្ដេចស្វាស្ទុំ បុគ្គលដែលកាន់អំណាចផ្តាច់ការរបស់ពួកគេនោះ។

ទាល់តែស្គាល់តម្លៃរបស់អាស្ហ៍លុលបៃត៍ عليهم السلام ទើបសុភាសិតនេះទៅជាពិតបាន។

កាលណាគេដឹងគុណតម្លៃនិងភាពរុងរឿងរបស់អ៊ីមុាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام កាលនោះគេអាចកាត់ថ្លៃបានយ៉ាងត្រឹមត្រូវនូវភ័យវិបត្តិឬគ្រោះមហន្តរាយដែលអាចពើបពះលើយើងបាន។

ដូច្នេះ ជួសការទួញសារទុក្ខបន្តិចបន្តួចក្នុងជីវិតនេះ គប្បីយំសោកសម្រក់ទឹកភ្នែករំលឹកគ្រោះមហន្តរាយអាស៊ូរ៉អ៊ុំនិងទុក្ខវេទនាដែលអ៊ីមុាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام បានទទួលរងនោះវិញ ដើម្បីរក្សាទុកឲ្យយើងនូវអ៊ីស្លាមបរិសុទ្ធ។ សូមឲ្យពរជ័យនិងសិរីសួស្តីកើតមានដល់អ៊ីមុាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام។ សូមឲ្យពួកសត្រូវទាំងឡាយរបស់ព្រះអង្គ صلوات الله عليه والسلام ត្រូវបណ្តាសារហូតដល់ថ្ងៃជំនុំជម្រះ។

## សង្ខេបព្រះវចនៈត្រចះត្រចង់របស់អ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام

-សម្រាប់ខ្ញុំ សេចក្តីស្លាប់ជាសុភមង្គល ចំណែកឯជីវិតរស់នៅជាមួយបុគ្គលអាក្រក់អន្យត្តិរ្ថិយនោះវិញជាកង្វល់។

-ហាមបន្ថោកបន្ទាបខ្លួនឯង។

-មនុស្សជាទាសៈរបស់ជីវិតនេះ ខណៈដែលពួកគេទើបនឹងបានស្គាល់សាសនា។ ពួកគេនៅតែកាន់សាសនានេះដរាបណាសាសនានេះផ្តល់ផលប្រយោជន៍ឲ្យពួកគេ។ តែកាលណាពួកគេជួបប្រទះវិបត្តិ កាលនោះកម្រមានអ្នកកាន់សាសនាណាស់។

-ប្រសិនបើអស់លោកមិនមានសមត្ថភាពទៅជាអ្នកមានសទ្ធាជ្រះថ្លាបានទេ យ៉ាងហោចណាស់ចូរអស់លោកទៅជាអ្នកមានសេរីភាពក្នុងជីវិតរបស់អស់លោក។



## អត្តសញ្ញាណ

-ត្រកូលនិងព្រះនាមខ្លួន ៖ អាល់-ហ៊ូសែន៍ ប៊ិន អ៊ាលី។

-ព្រះនាមល្បី ៖ ព្រះអគ្គមហាប្រមុខរបស់ទុក្ករៈបុគ្គលទាំងអស់។

-ព្រះនាមគោរព ៖ អាប៊ូ អ៊ាប់ឌុលឡោះហ៍។

-ព្រះនាមព្រះបិតា ៖ អ៊ាលី ប៊ិន អាប៊ូ ត៉ូលិប។

-ព្រះនាមព្រះមាតា ៖ ហ្វាទីម៉ាស់ អាស់ស្ហាស់រ៉អ៍ រាជបុត្រីរបស់មូហាំម៉ាដ់ﷺ។

-ថ្ងៃកំណើត ៖ ថ្ងៃទី ៣ ខែស្ហាក់បាន ឆ្នាំទី ៤ សករាជហ៊ីច្រ៉ោះត៍។

-ថ្ងៃពលីទុក្ករៈកម្ម ៖ ថ្ងៃទី ១០ ខែមូហារ៉ម ឆ្នាំទី ៦១ សករាជហ៊ីច្រ៉ោះត៍។

-កន្លែងបញ្ចុះព្រះរាជសព ៖ ការបាឡាអ៍។

-រយៈពេលអ៊ីម៉ាម៉ាស់របស់ព្រះអង្គ ៖ ១០ ឆ្នាំ។